## សេចក្ដីប្រកាសព័ត៌មានរួម

## ការប្រារព្ធយុទ្ធនាការ ១៦ថ្ងៃ នៃភាពសកម្មនិយមប្រឆាំង អំពើហិង្សាផ្អែកលើយេនឌ័រ

## ក្រោមប្រធានបទ៖

«លើកកម្ពស់សិទ្ធិអំណាចស្ត្រី និងក្មេងស្រី ដើម្បីរួចផុតពីអំពើហិង្សា និងការបៀតបៀនគ្រប់ទម្រង់ »

**រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤**

យើងខ្ញុំជាក្រុមអង្គការសង្គមស៊ីវិលដែលរួមមាន សមាគម សហជីព និងអង្គការមិនមែនរដ្ឋាភិបាល ដែលកំពុងធ្វើការងារដើម្បីលើកកម្ពស់សិទ្ធិការងារ សិទ្ធិស្ត្រី និងសមភាពយេនឌ័រនៅប្រទេសកម្ពុជា នឹងធ្វើការរៀបចំប្រារព្ធយុទ្ធនាការ ១៦ថ្ងៃ នៃភាពសកម្មនិយមប្រឆាំងអំពើហិង្សាផ្អែកលើយេនឌ័រ (ហៅកាត់ថា «យុទ្ធនាការ ១៦ថ្ងៃ») ក្រោមប្រធានបទ ៖ «លើកកម្ពស់សិទ្ធិអំណាចស្ត្រី និងក្មេងស្រី ដើម្បីរួចផុតពីការបៀតបៀតគ្រប់ទម្រង់ »។

យុទ្ធនាការនេះ មានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីយុទ្ធនាការ១៦ថ្ងៃ ផ្តល់ឱកាសដល់សកម្មជន ឬអ្នកការពារសិទ្ធិមនុស្សជាស្ត្រី ទាំងក្នុងវិស័យយេនឌ័រ និងវិស័យផ្សេងៗ លើកឡើងនូវបញ្ហាប្រឈមដែលពួកគេបានជួបប្រទះកន្លងមក ព្រមទាំងធ្វើការជួបជុំដើម្បីថ្លែងសារអំពីសំណូមពររបស់ពួកគេ ។ នៅឱកាសនោះដែរ សកម្មជន ឬអ្នកការពារសិទ្ធិមនុស្ស និងសិទ្ធិស្ត្រី នឹងស្នើសុំ ក៏ដូចជាជំរុញឱ្យរាជរដ្ឋាភិបាល គោរព និងការពារសិទ្ធិមនុស្សឱ្យបានម៉ឺងម៉ាត់ ជាពិសេសចំពោះអ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងដោះស្រាយបញ្ហាប្រឈមរបស់ស្ត្រី និងក្មេងស្រីឱ្យមានប្រសិទ្ធភាព។

អាស្រ័យហេតុនេះ សូមសាធារណជនជ្រាបជាព័ត៌មាន និងអញ្ជើញចូលរួមជាមួយយើងខ្ញុំក្នុងការប្រារព្ធទិវានេះតាមរយៈប្រព័ន្ធអនឡាញ និងដោយផ្ទាល់ ទៅតាមកាលវិភាគនៃសកម្មភាពដូចខាងក្រោម៖

- ថ្ងៃទី២៥ **ខែវិច្ឆិកា ឆ្នាំ២០២៤** យើងខ្ញុំចេញសេចក្តីប្រកាសព័ត៌មានស្តីពីការយុទ្ធនាការ ១៦ ថ្ងៃ នៃភាពសកម្មនិយមប្រឆាំងអំពើហិង្សាផ្អែកលើយេនឌ័រឆ្នាំ២០២៤ ។
- នៅចន្លោះពី**ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៤** យើងខ្ញុំនឹងរៀបចំកម្មវិធីវិទ្យុ និងផ្សាយបន្តផ្ទាល់នៅលើទំព័រហ្វេសប៊ុករបស់ស្ថាប័នដៃគូរៀបចំ លើប្រធានបទផ្សេងៗគ្នា ។
- ចាប់ពី**ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៤** យើងខ្ញុំនឹងចេញផ្សាយកម្រង វីដេអូខ្លីៗជាបន្តបន្ទាប់ស្តីអំពីតម្រូវការទាំង១៦ របស់ស្ត្រី និងក្មេងស្រី ។
- **នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤** យើងខ្ញុំនឹងបង្ហោះស៊ុមរូបថតយុទ្ធនាការនៅលើទំព័រហ្វេសប៊ុក ដើម្បីឱ្យសាធារណជនក្នុងបណ្តាញសង្គម អាចទាញយកទៅប្រើប្រាស់នៅលើគណនីហ្វេសប៊ុករបស់ពួកគេ ។
- ចាប់ពី**ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤** ដល់**ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ យើងខ្ញុំនឹងចេញផុស្ទ័ររាប់ថយក្រោយដើម្បីបង្ហាញពីថ្ងៃប្រារព្ធពិធីជួបជុំ នៅទីលានប្រជាធិបតេយ្យ រាជធានីភ្នំពេញ ។**
- **ចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤** យើងខ្ញុំនឹងរៀបចំកម្មវិធីសំណួរចម្លើយនៅលើប្រព័ន្ធអនឡាញ ដោយផ្តោតសំខាន់លើប្រធានបទទាក់ទងនឹងយុទ្ធនាការ១៦ថ្ងៃ ។

- នៅថ្ងៃ**ទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៤** យើងខ្ញុំនឹងចេញផ្សាយផ្ទាំងរូបភាព អញ្ជើញសាធារណជនឱ្យចូលរួម ជួបជុំផ្ទាល់នៅទីលានប្រជាធិបតេយ្យ នៅថ្ងៃទី០១ ខែធ្នូ ។
- នៅព្រឹកថ្ងៃទី**០១ ខែធ្នូ ឆ្នាំ២០២៤** យើងខ្ញុំនឹងរៀបចំកម្មវិធីជួបជុំផ្ទាល់ដែលមានអ្នកចូលរួមប្រមាណ ៥០០ នាក់ ក្រោមប្រធានបទ «លើកកម្ពស់សិទ្ធិអំណាចស្ត្រី និងក្មេងស្រី ដើម្បីរួចផុតពីការបៀតបៀនគ្រប់ទម្រង់»
- ចាប់ពី**ថ្ងៃទី២៥ ខែវិច្ឆិកា ដល់ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៤** យើងខ្ញុំនឹងបន្តចេញផ្សាយវីដេអូខ្លីជាបន្តបន្ទាប់ ដែលមានលើកឡើងអំពីតម្រូវការផ្សេងៗទៀតរបស់ស្ត្រី និងក្មេងស្រី ៕

**ព័ត៌មានបន្ថែម សូមទាក់ទង៖**

១. អ្នកស្រី អ៊ូ ទេពផល្លីន ទូរស័ព្ទ៖ ០១១ ៩៨៤ ៨៨៣

២. កញ្ញា កែវ ចាន់រ៉ា ទូរស័ព្ទ៖ ០៩៨ ៨៥២ ២៦០

៣. លោក លឹម បូរិន ទូរស័ព្ទ៖ ០១២ ៩០៤ ២៦៦

***បញ្ជីឈ្មោះអង្គការសង្គមស៊ីវិលសហការរៀបចំ៖**

*១. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (CTWUF)*
*២. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៏ (LRSU)*
*៣. សហជីពកម្មករចំណីអាហារនិងសេវាកម្ម (CFSWF)*
*៤. សហព័ន្ធសហជីពកម្ពុជា (CATU)*
*៥. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ(IDEA)*
*៦. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស CENTRAL)*
*៧. បណ្តាញយុវជនកម្ពុជា (CYN)*
*៨. អង្គការសមធម៌កម្ពុជា (EC)*
*៩. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)*
*១០. អង្គការសមាគមជាងត្នោត (STT)*
*១១. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)*
*១២. សម្ព័ន្ធខ្មែរជំរឿននឹងការពារសិទ្ធិមនុស្ស (LICADHO)*
*១៣. អង្គការក្លាហាន (Klahaan)*
*១៤. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)*
*១៥. សហព័ន្ធសហជីពឯករាជ្យ ( INTUFE )*
*១៦. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)*
*១៧. អង្គការអោក់សិនអេតកម្ពុជា(AAC)*
*១៨. សម្ព័ន្ធភាពជាដៃគូរដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)*
*១៩. សមាគមស្ត្រីជនបទដើម្បីកៀរគ្របវិស្ថាន (RWAA)*